# ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គឈានដល់ការសម្រេចលើបញ្ហាបន្ទាន់នានា

**បាងកក ប្រទេសថៃ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៤**—ប្រតិភូថ្នាក់រដ្ឋមន្ត្រីនៃក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ បានអះអាងនៅថ្ងៃនេះអំពីការពាក់ព័ន្ធនៃអង្គការនេះជាវេទិកាសហប្រតិបត្តិការថ្នាក់តំបន់មួយ ដោយបានឯកភាពលើបញ្ហាគន្លឹះមួយចំនួនរួមទាំងការបង្កើនល្បឿននៃការសិក្សារបស់ក្រុមប្រឹក្សានេះ ដែលជាកំណែទម្រង់វិមជ្ឈការ និងដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងថាមពលវារីអគ្គិសនីដនសាហុង។

ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ គឺជាអង្គការខ្ពស់បំផុតថ្នាក់រដ្ឋមន្ត្រីដែលមានរដ្ឋមន្ត្រីក្រសួងធនធានទឹក និងបរិស្ថានមកពីប្រទេសជាសមាជិកទាំងបួនគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម។ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ ក្រុមប្រឹក្សានេះសង្កត់ធួន់អំពីតម្រូវការឲ្យបង្កើនល្បឿន*ការសិក្សារបស់ក្រុមប្រឹក្សានេះអំពី**ការគ្រប់គ្រង និងការអភិវឌ្ឍទន្លេមេគង្គដោយចីរភាព ដែលរួមទាំងផលប៉ះពាល់នៃគម្រោងថាមពល**វារីអគ្គិនីលើដងទន្លេមេផងដែរ*។

ការសិក្សានេះមានគោលដៅផ្តល់ទិដ្ឋភាពប្រសើរជាមុនមួយអំពីផលប៉ះពាល់ឆ្លងដែនដែលអាចកើតមាន បណ្តាលពីសកម្មភាពអភិវឌ្ឍន៍នៅក្នុងដងទន្លេមេនៃទន្លេមេគង្គ។ ការសិក្សា ដែលកំពុងដំណើរការ និងដែលនឹងផ្តោតលើប្រធានបទនានាទាក់ទងនឹងកសិកម្ម ការស្រោចស្រព ការប្រើប្រាស់ទឹកសម្រាប់លំនៅដ្ឋាន និងក្នុងឧស្សាហកម្ម កិច្ចការពារទឹកជំនន់ និងការអភិវឌ្ឍថាមពលវារីអគ្គិសនី និងនាវាចរ ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ មានគោលដៅបំពេញភាពខ្វះចន្លោះខាងចំណេះដឹង និងការយល់ដឹងអំពីប្រធានបទទាំងនេះ។

ចំណុចសំខាន់បំផុតមួយនៅក្នុងរបៀបវារៈដែលកិច្ចប្រជុំបានពិភាក្សា គឺគណៈកម្មារទន្លេមេគង្គ បានចាប់ផ្តើមកំណែទម្រង់ស្ថាប័នដើម្បីធ្វើវិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ មកប្រទេសសមាជិក។ កិច្ចប្រជុំនេះបានឯកភាពលើអនុសាសន៍នានាដែលផ្តល់ដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដើម្បីអនុវត្តដំណើរការនេះ ដែលនឹងបង្កើនប្រសិទ្ធផល និងប្រសិទ្ធភាពនៃអង្គការនេះ និងប្រែក្លាយស្ថាប័ននេះទៅជាអង្គភាពមួយដែលមានស្វ័យភាពហិរញ្ញវត្ថុចាប់ពីឆ្នាំ ២០៣០ តទៅ។ វិមជ្ឈការគឺជាដំណើរការជាជំហានៗ ដែលរួមមានកំណែទម្រង់រចនាសម្ព័ន្ធ បុគ្គលិក និងហិរញ្ញវត្ថុ។ គោលដៅមួយក្នុងចំណោមគោលដៅសំខាន់ៗគឺ ការធានាឲ្យមានប្រតិបត្តិការប្រកបដោយការសម្របសម្រួលនៅថ្នាក់តំបន់ និងថ្នាក់ជាតិ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ប្រតិភូឡាវបានពោលថា ខ្លួននឹងដាក់ជូនឡើងវិញនូវគម្រោងថាមពលវារី

អគ្គិសនីដនសាហុង នៅក្រោមដំណើរការពិគ្រោះយោបល់ជាមុន។ គម្រោងនេះត្រូវបានដាក់ជូនមកគណៈកម្មការទន្លេមេគង្គរួចម្តងមកហើយនៅក្រោមដំណើរការនៃការជូនដំណឹង។ ការពិគ្រោះយោបល់ជាមុន នឹងបង្កើតជាផ្លូវការនូវការពិភាក្សា និងការវាយតម្លៃក្នុងចំណោមប្រទេសជាសមាជិក និងភាគីពាក់ព័ន្ធនានាអំពីឥទ្ធិពល

ឆ្លងដែនអវិជ្ជមានដែលទំនងជាកើតឡើងបណ្តាលពីគម្រោងនេះ។ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គនឹងសម្រួលដល់ការអនុវត្តដំណើរការនេះ។

កិច្ចប្រជុំនៃក្រុមប្រឹក្សានេះក៏បានពិភាក្សាផងដែរអំពីកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃអង្គការនេះ។ កិច្ចប្រជុំនេះដែលមានរយៈពេលពីរថ្ងៃ នឹងត្រូវបញ្ចប់នៅថ្ងៃ២៧ ខែ មិថុនា។

## កំណត់សំគាល់សម្រាប់និពន្ធនាយកៈ

គណៈកម្មការទន្លេមេគង្គ គឺជាអង្គការអន្តររដ្ឋាភិបាលមួយដែលមានភារៈទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងអាងទន្លេមេគង្គដោយនិរន្តរភាព ដែលមានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមជាសមាជិក។ អង្គការនេះត្រូវបានបង្កើតឡើងដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេស ជាសមាជិក និងមិនមែនជាអង្គភាពនិយ័តកម្ម ឬ អង្គភាពនៅខ្ពស់ជាងថ្នាក់ជាតិឡើយ។

ការពិគ្រោះយោបល់ជាមុនគឺជាដំណើរការមួយនៅក្រោមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដែលមានគោលដៅអនុញ្ញាតឲ្យ ប្រទេសជាសមាជិកដទៃទៀតនៅតាមដងទន្លេនេះ ពិភាក្សា និងវាយតម្លៃអំពីផលប៉ះពាល់ឆ្លងដែនអំពីសំណើនៃការប្រើប្រាស់ ដែលជាមូលដ្ឋានសម្រាប់ការឈានដល់ដំណោះស្រាយដោយសមធម៌សម្រាប់គម្រោង ដើម្បីបញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយ ឥទ្ធិពលប្រកបដោយគ្រោះថ្នាក់មកលើបរិស្ថាន ជាពិសេស គុណភាព និងបរិមាណទឹក។ នេះមិនមែនជាដំណើរការនៃការសម្រេចលើគម្រោងឡើយ។

ដំណើរការជូនដំណឹង ក៏ស្ថិតក្រោមនីតិវិធី PNPCA ផងដែរ និងជាលក្ខខណ្ឌចាំបាច់សម្រាប់ការរៀបចំគម្រោងប្រើប្រាស់ទឹកណាមួយ ដែលស្នើឡើងសម្រាប់អនុវត្តលើដៃទន្លេ និងដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើទន្លេមេ ឬ នៅលើទន្លេមេនៃដងទន្លេមេគង្គ នៅក្នុងរដូវវស្សា ដោយគ្មានការបង្វែរទឹករវាងអាងទន្លេខុសគ្នា។ ដំណើរការនេះទាមទារឲ្យមានការជូនដំណឹងដល់គណៈកម្មារទន្លេមេគង្គ និងការដាក់ជូនព័ត៌មានពាក់ព័ន្ធនៃគម្រោង ដើម្បីអាចឲ្យប្រទេសដែលបានទទួលដំណឹងនេះ ដឹងជាមុនអំពីការប្រើប្រាស់ទឹកពីសំណាក់គម្រោងនោះ និងផលប៉ះពាល់ធ្ងន់ធ្ងរណាមួយដែលអាចកើតចេញពីគម្រោងនោះ។

-ចប់-

ចំពោះព័ត៌មានបន្ថែម សូមទាក់ទងៈ លោក ស៊ូរ៉ាសាក់ ក្លាហាន មន្ត្រីទំនាក់ទំនង នៅការិយាល័យនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ក្នុងក្រុងវៀងច័ន្ទតាមអ៊ីម៉ែល:Surasak@mrcmekong.org ឬតាមទូរស័ព្ទ +856 263 263 លេខបន្ត 4067 ឬ +856 20 7850 6220 (លេខទូរស័ព្ទចល័តនៅវៀងច័ន្ទ) ឬ +66 86 636 6690 (លេខទូរស័ព្ទចល័តនៅវាងថ្ងៃ 25 – 27 ខែមិថុនា) ។